# យុត្តិធម៌អន្តរកាលតាមរយៈការស្តាប់សំឡេងស្ត្រីកម្ពុជា

បេនី យេ[១]

*តុលាការអន្តរជាតិនិងតុលាការចម្រុះត្រូវបានបង្កើតឡើងតាមរយៈយន្តការយុត្តិធម៌អនរកាល ។ នៅក្នុងប្រទេសកម្ពុជា តុលាការចម្រុះមួយដែលមានការចូលរួមពីសំណាក់ភាគីជាតិ និងអន្តរជាត ត្រូវបានបង្កើត ព្រមទាំងដាក់ឲ្យដំណើរការក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយតុលាការនេះត្រូវបានមើលឃើញថាជាយន្តការផ្លូវការតែមួយគត់សម្រាប់ដោះស្រាយបញ្ហាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលនៃរបបខ្មែរក្រហម ។ ដោយសារតែមានការកំណត់ចំពោះអាណត្តិនៃការងារ និងកង្វះខាតផ្នែកថវិកា តុលាការនេះពុំអាចធ្វើការស៊ើបអង្កេតទៅលើរាល់ព្យសនកម្មដែលកើតឡើងចំពោះជនរងគ្រោះនៃរបបខ្មែរក្រហមទាំងស្រុងបានទេ ។ អត្ថបទនេះនឹងបង្ហាញអំពីតម្លៃនៃយន្តការយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការ ដែលជាវិធីសាស្ត្របំពេញបន្ថែម ដោយប្រើប្រាស់នូវបទពិសោធន៍ស្តីពីការស្តាប់សំឡេងរបស់ស្ត្រី ដែលលើកឡើងទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងស្ថានភាពកំពុងមានវិវាទកម្ម ។ ការសិក្សាលើបញ្ហាទាំងនេះត្រូវបានឡើងនៅក្នុងប្រទេសកម្ពុជា ដែលរៀបចំឡើងដោយគម្រោងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា នៅក្នុងឆ្នាំ២០១១, ២០១២ និង ២០១៣ ។*

១) សេចក្តីផ្តើម ........ ២
២) ការស្តាប់សំឡេងស្ត្រីនៅក្នុងប្រទេសកម្ពុជា ........ ៦
៣) ការស្តាប់សំឡេងស្ត្រីជាយន្តការសម្រាប់យុត្តិធម៌អន្តកាល ........ ៨
   ៣.១ ធាតុផ្សំទាក់ទងនឹងការពិត ........ ៩
   ៣.២ ធាតុផ្សំទាក់ទងនឹងយុត្តិធម ........ ១២
   ៣.៣ ធាតុផ្សំទាក់ទងនឹងសំណង ........ ១៣
   ៣.៤ ធាតុផ្សំដែលធានាមិនឲ្យមានអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត ........ ១៦

---

[១] *ជាទីប្រឹក្សាច្បាប់នៅ REDRESS និងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អតីតទីប្រឹក្សាសេវាកម្មសន្តិភាពស៊ីវិលក្នុងគម្រោងការពារសិទ្ធិកម្ពុជានៅទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ ។*

៤) ការស្តាប់សំឡេងស្ត្រីជាយន្តការបំពេញបន្ថែមសម្រាប់តុលាការ និងជាគណៈកម្មការការស្វែងរកការពិត............................................................................................. ១៩
៥) សេចក្តីសន្និដ្ឋាន..........................................................................................................២១

## ១) សេចក្តីផ្តើម

ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ដែលស្គាល់ជាទូទៅថា ខ្មែរក្រហម បានចូលមកគ្រប់គ្រងប្រទេស និងប្តូរឈ្មោះរបបរបស់ខ្លួនទៅជា របបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រទេសទាំងមូលត្រូវបានផ្លាស់ប្តូរទៅជាជំរំការងារដ៏ធំមួយ អមទៅដោយមន្ទីរឃុំឃាំងជាច្រើន ដើម្បីសម្រេចផែនការ"បដិវត្តន៍សង្គមនិយម" ។ ប្រជាជនត្រូវបានបង្ខំឲ្យ ធ្វើការងារយ៉ាងលំបាកក្នុងស្ថានភាពអមនុស្សធម៌ ។ ជាលទ្ធផលមានមនុស្សរាប់លាននាក់ត្រូវបានស្លាប់ដោយសារតែការអត់ឃ្លាន ជំងឺ និងស្ថានភាពរស់នៅដ៏អាក្រក់ក្រៃលែង ។ ក្នុងពេលជាមួយគ្នានេះដែរ បក្សកុម្មុយនីស្តកម្ពុជា បានស្វែងរកឥតឈប់ឈរដើម្បីកម្ចាត់ចោលជនទាំងឡាយណាដែលខ្លួនចាត់ទុកជាខ្មាំងរបស់បដិវត្តន៍ ។ នៅក្នុងអំឡុងពេលជិតបួនឆ្នាំ ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ទ្រង់ទ្រាយធំចំពោះប្រជាជនស្លូតត្រង់បានក្លាយទៅជារឿងសាមញ្ញ ។ បើតាមការប៉ាន់ប្រមាណមានប្រជាជនប្រហែលពីរលាននាក់ ដែលបានស្លាប់នៅក្នុងអំឡុងពេលនោះ ។

មានករណីជាច្រើនដែលយើងមិនបានដឹងទាក់ទងនឹង អំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រចំពោះស្ត្រី[២] ដែលត្រូវបានប្រព្រឹត្តឡើង រួមជាមួយនឹងការសម្លាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ។ តាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ២០០៨ និងនៅក្នុងឆ្នាំ២០១១ គេបានធ្វើការវិភាគលើចរិតលក្ខណៈនៃអំពើហិង្សា និងសន្និដ្ឋានថា បទល្មើសនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រជាច្រើនករណីពិតជាបានកើតឡើងមាននៅក្នុងអំឡុងពេលនៃរបបនោះ ។[៣] បទឧក្រិដ្ឋទាំងនោះរួមមាន ៖ ការរំលោភ

[២] អត្ថបទនេះផ្តោតលើបទពិសោធន៍របស់ស្ត្រីដែលធ្លាប់ជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ។ បទពិសោធន៍របស់បុរសនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ត្រូវបានរាយការណ៍ ប៉ុន្តែនៅមិនទាន់មានការស្រាវជ្រាវណាមួយជាក់លាក់ទេ ។

[៣] សូមមើល Nakagawa Kasumi, *Gender-Based Violence During the Khmer Rouge Regime – Stories of Survivors from the Democratic Kampuchea* (មីនា, ២០០៨), អាចមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2013/02/Kasumi-GBV-Study-2007.pdf; Katrina Natale, *I Could Feel My Soul Flying Away From My Body — A Study on Gender-Based Violence During Democratic Kampuchea in Battambang and*

សេពសន្ថវៈ ការរំលោភជាក្រុមដោយមានជនល្មើសច្រើននាក់ ការរំលោភទ្រង់ទ្រាយមួយដែលមានជនរងគ្រោះច្រើនក្នុងពេលតែមួយ ការរំលោភដោយប្រើប្រាស់ឧបករណ៍ ការបង្ខំឲ្យអាក្រាតកាយ ការកេងប្រវ័ញ្ចខាងផ្លូវភេទ និងការរៀបការដោយបង្ខំដែលបានអនុវត្តនៅទូទាំងប្រទេស ។

ដើម្បីធ្វើការកាត់ទោសចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅអំឡុងពេលគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា តុលាការចម្រុះចូលរួមដោយសមាសភាពភាគីជាតិ និងអន្តរជាតិត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៣ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានយុត្តាធិការជំនុំជម្រះលើមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ បច្ចុប្បន្ន តុលាការនេះ គឺជាស្ថាប័នតែមួយគត់ ដែលមានសមត្ថកិច្ចធ្វើការជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបនោះ ។

នៅក្នុងសំណុំរឿងទាំងបួនដែលកំពុងដំណើរការ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ទទួលបានការចាប់អារម្មណ៍តិចតួចប៉ុណ្ណោះរហូតមកដល់ពេលបច្ចុប្បន្ននេះ ។ ជនជាប់ចោទដែលមានតួនាទីថ្នាក់កណ្តាលមួយរូប ត្រូវបានរកឃើញថាមានពិរុទ្ធពាក់ព័ន្ធនឹងករណីប្រើប្រាស់ការរំលោភដើម្បីធ្វើទារុណកម្ម (សំណុំរឿង០០១) ។[៤] ជនជាប់ចោទពីរនាក់ទៀត ដែលជាអតីតមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមត្រូវបានចោទប្រកាន់ទៅលើករណីរៀបការដោយបង្ខំ ដោយរាប់បញ្ចូលបទល្មើសរំលោភសេពសន្ថវៈ ដែលត្រូវបានចាត់ចូលទៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[៥] ប៉ុន្តែបទល្មើសនេះមិនទាន់ត្រូវបានលើកយកមកធ្វើការជំនុំជម្រះនៅក្នុងសំណុំ

---

*Svay Rieng Provinces* (វិច្ឆិកា,២០១១), អាចមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2013/0I/Natale_K_Research_GBV_KR_ENG-web.pdf.

[៤] សូមមើលសាលក្រម, សំណុំរឿង០០១/១៨-០៧/២០០៧/អ.វ.ត.ក./TC., កថាខណ្ឌ២៤០, ៣៦៦ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) ។

[៥] សូមមើលដីកាដំណោះស្រាយក្នុងសំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក.-OCIJ, កថាខណ្ឌ៨៥៨-៦០, ១៤៣០-៣៣, ១៥៤៥ (ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០) បទចោទទាក់ទងនឹងការរៀបការដោយបង្ខំត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់ពីមានការស្នើសុំឲ្យមានការស៊ើបអង្កេតដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ។ សូមមើល Co-Lawyers for the Civil Parties' Fourth Investigative Request Concerning Forced Marriages and Sexually Related Crimes, សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក.-កសចស (ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៩), ដីកាស្តីពីសំណើសុំឲ្យមានការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការបង្ខំឲ្យមានទំនាក់ទំនងផ្លូវភេទ, សំណុំរឿង០០២ /១៩-០៩-២០០៧-អ.វ.ត.ក-កសចស (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩) ។

រឿង០០២ទេ។[៦] គ្មានទម្រង់ណាមួយនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងដីកាចោទប្រកាន់លើបទឧក្រិដ្ឋទូទាំងប្រទេសប្រឆាំងនឹងជនជាប់ចោទទាំងនោះឡើយទេ ទោះបីជាអ្នកស៊ើបអង្កេតបានរកឃើញថា មានបទល្មើសរំលោភត្រូវបានប្រព្រឹត្តនៅទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ។[៧] បើយោងតាម ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានសមត្ថកិច្ចចេញដីកាដំណោះស្រាយបានកំណត់ថា «គោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការរំលោភសេពសន្ថវៈ បានចែងអំពីការហាមឃាត់មិនឲ្យមានអំពើរំលោភកើតឡើង និងផ្តន្ទាទោសជនទាំងឡាយណាដែលបានប្រព្រឹត្ត ។ តែផ្ទុយមកវិញ គោលនយោបាយនេះ មិនបានទប់ស្កាត់ករណីរំលោភនោះទេ ដូច្នេះយើងពុំអាចធ្វើការសន្និដ្ឋានថា ករណីរំលោភ គឺជាបទល្មើសមួយនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដើម្បីអនុវត្តគោលបំណងរួមនោះទេ ។»[៨] ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើមួយ ដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី នៅមុនពេលសំណុំរឿង០០២ចាប់ផ្តើមដំណើរការ[៩] ដែលបានសុំឲ្យដាក់បញ្ចូលបទចោទប្រកាន់ពាក់ព័ន្ធនឹងបទល្មើសរំលោភ ដែលមិនស្ថិតនៅក្នុងករណីរៀបការដោយបង្ខំទៅក្នុងសំណុំរឿងនេះ ។[១០]

ដោយសារការរក្សាសម្ងាត់ គឺជាវិជ្ជាជីវៈរបស់តុលាការ មានសំណុំរឿងពីរទៀតដែលនៅសល់ (សំណុំរឿង០០៣ និង ០០៤) សំណុំរឿងទាំងពីរនេះបានស្ថិតនៅក្រោមការស៊ើបអង្កេតរបស់

[៦] ជនជាប់ចោទពីរនាក់ក្នុងចំណោមជនជាប់ចោទបួនរូបដែលមានអាយុលើសពី៨០ឆ្នាំ នៃសំណុំរឿង០០២ ត្រូវបានដកចេញពីដំណើរការនៃការកាត់ទោស ៖ ជនជាប់ចោទមួយរូបត្រូវដកចេញដោយសារតែកើតជំងឺវិកលចរិត និងជនជាប់ចោទមួយរូបផ្សេងទៀតបានស្លាប់កាលពីខែមនា ឆ្នាំ២០១៣ នៅអំឡុងពេលនៃដំណើរការកាត់ទោស ។ ដោយសារតែជនជាប់ចោទមានអាយុច្រើន និងមានការព្រួយបារម្ភថាអ្នកទាំងនោះមិនអាចរស់បានដល់មានសាលក្រមសម្រេចសេចក្តី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកបទចោទដែលមាននៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ក្នុងគោលបំណងជំនុំជម្រះអង្គហេតុនីមួយៗទៅតាមលំដាប់លំដោយដែលទាក់ទងទៅនឹងផ្នែកផ្សេងៗគ្នានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ សូមមើល ដីកាសម្រេចបំបែកសំណុំរឿង អនុលោមតាមវិធានផ្ទៃក្នុង៨៩ស្ទួនពីរ, សំណុំរឿង០០២/០២, សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក./TC, កថាខណ្ឌ៣៣ (ថ្ងៃទី៤ខែមេសា ឆ្នាំ២០១៤) ។

[៧] ដីកាដំណោះស្រាយ, សូមមើលកំណត់សម្គាល់ទី៥ខាងលើ, កថាខណ្ឌ១៤២៦-២៧ ។

[៨] ដដែល ដូចខាងលើ ។ កថាខណ្ឌ១៤២៩ ។

[៩] សូមមើល សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបទៅនឹង សំណើរបស់សហព្រះរាជអាជ្ញាដើម្បីកែសម្រួលលក្ខណៈអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក./TC (ថ្ងៃទី២១ខែកក្កដា ឆ្នាំ២០១៤) ។

[១០] សូមមើល អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន, ព័ត៌មានបន្ថែមទាក់ទងនឹងការជំទាស់នឹងអញ្ញត្រកម្ម, កថាខណ្ឌ៣៣ (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤) ។

តុលាការចាប់តាំងពីឆ្នាំ២០០៩ និងពុំទាន់ប្រកាសជាសាធារណៈអំពីវិសាលភាពនៃការស៊ើបអង្កេតចំពោះអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រទេ។ ទោះបីជាយ៉ាងណា នៅក្នុងខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យមានការចោទប្រកាន់ទៅលើជនសង្ស័យថ្នាក់តំបន់ បីរូប ដើម្បីពង្រីកវិសាលភាពនៃការស៊ើបអង្កេតទាក់ទងនឹងអំពើហិង្សាផ្លូវភេទ បន្ថែមពីលើបរិបទនៃការរៀបការដោយបង្ខំ។[១១] ដោយសារតែមានការជំទាស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាតាំងយូរមកហើយទាក់ទងនឹងសំណុំរឿងទាំងនេះ បូករួមទាំងបញ្ហាហិរញ្ញវត្ថុរបស់តុលាការដែលមានលក្ខណៈពុំច្បាស់លាស់ ដូច្នេះទោះបីជាមាន ការវិវត្តល្អប្រសើរយ៉ាងណាក៏ដោយ នៅតែមានភាពមិនច្បាស់លាស់ថា តើជនសង្ស័យទាំងនោះ នឹងត្រូវបាននាំយកមកកាត់ទោសឬយ៉ាងណា។

ប្រសិនបើដូចជាអ្វីដែលបានរំពឹងទុក ដែលថា មេដឹកនាំជាន់ខ្ពស់ទាំងពីររូប គឺជនជាប់ចោទចុងក្រោយដែលត្រូវបាននាំយកមកកាត់ទោស នោះអ្នកដែលរស់រានមានជីវិតក្រោយអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នឹងមានឱកាសបានត្រឹមតែបកស្រាយអំពីចំណុចមួយចំនួនទាក់ទងនឹងបទពិសោធន៍ផ្ទាល់របស់គាត់តែប៉ុណ្ណោះ។ ឧទាហរណ៍ ៈ អ្នកដែលរស់រានមានជីវិតក្រោយការរៀបការដោយបង្ខំ ហើយធាបត្រូវបានគេរំលោភនៅក្នុងគុក នឹងមិនមានឱកាសមកផ្តល់សក្ខីកម្មអំពីបទល្មើសអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ទាំងស្រុងនោះទេ។[១២] ជាមួយគ្នានេះដែរ រឿងរ៉ាវដែលមិនត្រូវបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ នឹងមិនត្រូវបានដាក់បញ្ចូលទៅក្នុងកំណត់ត្រាប្រវត្តសាស្រ្តដែលសរសេរដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ តាមរយៈការដាក់បញ្ចូលទៅក្នុងសាលក្រមរបស់តុលាការ ដូច្នេះវាកាន់តែធ្វើឲ្យប្រជាជនជឿជាក់ថាករណីរំលោភ មិនបានកើតមាននៅក្នុងរបបខ្មែរក្រហមនោះទេ គឺមានតែនៅបរិបទនៃការរៀបការដោយបង្ខំប៉ុណ្ណោះ។ ចំពោះទស្សនៈជុំវិញចំណុចចន្លោះប្រហោងនេះ ហាក់បីដូចជាត្រូវបានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ទុកចោលដោយមិនលើកយកមកពិភាក្សា ហើយកម្រិតនៃការបាត់បង់រឿងរាវទាំងអស់នេះទៅតាមពេលវេលាដែលកន្លងទៅនឹងមាន

[១១] សេចក្តីប្រកាសព័ត៌មាន, សំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការស៊ើបអង្កេតទៅលើបទចោទប្រកាន់អំពីបទហិង្សាផ្លូវភេទ និងយេនឌ័រ នៅក្នុងសំណុំរឿង០០៤ (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤), អាចមើលបានលើគេហទំព័រ www.eccc.gov.kh/en/articles/international-co-prosecutor-requests-investigation-alleged-sexual-and-gender-based-violence.

[១២] អ្នកដើមបណ្តឹងម្នាក់ត្រូវបានគាំទ្រដោយគម្រោងការការពារប្រជាជនកម្ពុជាដែលធ្លាប់ជួបប្រទះរឿងរ៉ាវនេះ។

កាន់តែខ្ពស់ឡើងៗ ។ ហេតុដូចនេះហើយ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា[១៣] យល់ឃើញថាវាចាំបាច់ដើម្បីចាត់វិធានការជាបន្ទាន់ ។

## ២) ការស្តាប់សំឡេងស្ត្រីនៅក្នុងប្រទេសកម្ពុជា

នៅក្នុងឆ្នាំ២០១១ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានចាប់ផ្តើមរៀបចំវេទិកាស្តាប់សំឡេងរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជាជាលើកដំបូង ។ វេទិកាស្តាប់សំឡេងរបស់ស្ត្រីចំនួនពីរទៀតត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ នៅក្នុងឆ្នាំ២០១២ និង២០១៣ ដែលមានប្រធានបទខុសៗគ្នាសម្រាប់ឆ្នាំនីមួយៗ ។ វេទិកាស្តាប់សំឡេងរបស់ស្ត្រីទាំងនេះផ្តោតលើទម្រង់ដូចគ្នា ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកផ្តល់សក្ខីកម្មជាសាធារណៈ មុនពេលចូលផ្តល់នៅចំពោះមុខគណៈវិនិច្ឆ័យ ។ ការជ្រើសរើសឲ្យមានទម្រង់មួយច្បាស់លាស់នេះ ទទួលបានការលើកទឹកចិត្តយ៉ាងខ្លាំងពីសំណាក់គណៈកម្មាការស្វែងរកការពិត ដែលសម្រេចបានការដោះស្រាយបញ្ហាអំពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ នៅអំឡុងពេលនៃជម្លោះ[១៤] ជាពិសេសគឺ គណៈកម្មាការសម្រាប់បដិសណ្ឋារកិច្ច ស្វែងរកការពិត និងផ្សះផ្សានៅប្រទេសទីម័រខាងកើត បានរៀបចំវេទិកាដាច់ដោយឡែកសម្រាប់ស្តាប់សំឡេងរបស់ស្ត្រី និងគំនិតផ្តួចផ្តើមផ្សេងៗទៀតរបស់សង្គមស៊ីវិល ដូចជាតុលាការសម្រាប់រឿងក្តីរបស់ស្ត្រី ។[១៥] ដំណើរការវេទិកាស្តាប់សំឡេងរបស់ស្ត្រីនៅកម្ពុជា ត្រូវបានចងក្រងជាឯកសារក្នុងទម្រង់ជារបាយការណ៍ និងខ្សែភាពយន្ត ។[១៦]

នៅក្នុងឆ្នាំ២០១១ វេទិកាស្តាប់សំឡេងរបស់ស្ត្រី បានផ្តោតទៅលើប្រធានបទអំពើហិង្សាផ្លូវភេទនៅក្នុងប្រទេសកម្ពុជានៅអំឡុងពេលនៃរបបខ្មែរក្រហម ។ ដើម្បីធ្វើឲ្យប្រធានបទនេះមានអត្ថន័យ

---

[១៣] គម្រោងការការពារសិទ្ធិកម្ពុជា គឺជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុកដែលផ្តល់នូវជំនួយផ្នែកច្បាប់សម្រាប់ការពារការរំលោភសិទ្ធិមនុស្ស និងជនរងគ្រោះ រួមមាន អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម និងជម្លោះក្នុងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ។ សូមមើល www.cdpcambodia.org and gbvkr.org សម្រាប់ព័ត៌មានបន្ថែម ។

[១៤] ទស្សនៈទូទៅជុំវិញវិធីសាស្ត្រដែលគណៈកម្មាធិការស្វែងរកការពិតបានដោះស្រាយជាមួយនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រនៅក្នុងជម្លោះ, សូមមើល University of Wyoming Center for International Human Rights Law & Advocacy, Background Paper on Dealing with Gender-Based Violence in Transitional Justice for Asia-Pacific Regional Women's Hearing on Gender-Based Violence in Conflict (ខែតុលា ឆ្នាំ២០១២) ។

[១៥] សូមមើល ការណែនាំរបស់តុលាការស្ត្រី, http://weap.prg/news/386/17/The -court-of-Women.htm

[១៦] សេចក្តីរាយការណ៍អាចយកបានតាមរយៈ www.gbvkr.org/publications-and-materials/reports. អាចមើលបានតាមរយៈ www.gbvkr.org/publications-and-materials/audio-visual-material/

កាន់តែទូលាយ នៅក្នុងឆ្នាំ២០១២ វេទិកាស្តាប់សំឡេងស្ត្រីនៃតំបន់អាស៊ីប៉ាស៊ីហ្វិក បានរៀបចំវេទិកាស្តីពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងស្ថានភាពដែលមានវិវាទកម្ម ដោយស្តាប់សក្ខីកម្មរបស់ស្ត្រីដែលមកពីបីប្រទេសផ្សេងគ្នានៅក្នុងតំបន់ដែលធ្លាប់មានជម្លោះប្រដាប់អាវុធ ។ ក្រុមគោលដៅសម្រាប់ឆ្នាំ២០១៣ ត្រូវបានផ្លាស់ប្តូរពីទស្សនិកជនអន្តរជាតិ ទៅជាប្រជាជនកម្ពុជាជំនាន់ថ្មីក្រោយសម័យសង្គ្រាម ដោយអ្នកជំនាន់ក្រោយទាំងនេះ ភាគច្រើនមិនទាន់ស្គាល់ច្បាស់អំពីប្រវត្តសាស្ត្រនៃរបបខ្មែរក្រហមទេ ហើយការយល់ដឹងអំពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័ររបស់គេក៏នៅមានកម្រិតដែរ ។

វេទិកាទាំងបីដែលរៀបចំឡើងដើម្បីស្តាប់សំឡេងរបស់ស្ត្រី បានព្យាយាមនាំមកនូវវេទិកាយុត្តិធម៌អន្តរកាលក្រៅប្រពន្ធ័តុលាការមួយ ដើម្បីដោះស្រាយករណីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រនៅក្នុងវិវាទកម្មដែលកើតមានកាលពីអតីតកាល ។ វេទិកានេះមានគោលដៅផល់សិទ្ធិស្របច្បាប់ដល់ជនរងគ្រោះដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដែលនៅរស់រានមានជីវិត ដោយផ្តល់ឲ្យពួកគាត់នូវសំឡេងដើម្បីទម្លាយភាពស្ងៀមស្ងាត់ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនេះ និងដើម្បីបង្ហាញអំពីតម្រូវការរួមជាមួយការទាមទាររបស់ពួកគាត់ ។ អ្នកដែលរស់រានមានជីវិត ត្រូវបានគោរពកោតសរសើរជាសាធារណៈ ចំពោះទុក្ខវេទនា ភាពរឹងមាំ និងសេចក្តីក្លាហានរបស់ពួកគាត់ ដែលតតាំងនឹងការមាក់ងាយ ព្រមទាំងការរើសអើងចំពោះអ្នកដែលនៅរស់រានមានជីវិត តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះដែលពួកគាត់បានជួបប្រទះ និងការព្រួយបារម្ភនានា ព្រមទាំងបង្កើតឲ្យមានការបង្ក្រងប្រវត្តិសាស្ត្រមួយដែលមានភាពសុក្រឹតជាងនេះ ដោយរក្សាទុកជាឯកសារអំពីបទពិសោធន៍នានារបស់អ្នកដែលនៅរស់រានមានជីវិត ។

ចំណែកឯគណៈវិនិច្ឆ័យ នៅក្នុងឆ្នាំ ២០១១ និង ២០១២វិញ ត្រូវបានរួមបញ្ចូលនូវសមាសភាពអ្នកជំនាញផ្នែកច្បាប់ និងបញ្ហាយេនឌ័រ ទាំងជាតិ និងអន្តរជាតិ ។ គណៈវិនិច្ឆ័យនៅក្នុងឆ្នាំ ២០១៣ ត្រូវបានបំពេញការងារ ដោយក្រុមនិស្សិតមកពីបណ្តាសាកលវិទ្យាល័យនានានៅក្នុងប្រទេសកម្ពុជា ។ រៀងរាល់ឆ្នាំ គណៈវិនិច្ឆ័យនីមួយៗបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ដោយដាក់បញ្ចូលនូវបញ្ហានានាដែលបានរកឃើញ និងផ្តល់អនុសាសន៍នានា ចំពោះភាគីមួយចំនួនដែលពាក់ព័ន្ធ ។[១៧]

[១៧] មើលក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា, សេចក្តីរាយការណ៍២០១១ អំពីដំណើរការវេទិកាស្តាប់សំឡេងស្ត្រីស្តីពីអំពើហិង្សាផ្លូវភេទនៅក្នុងរបបខ្មែរក្រហម(ខែឧសភា ឆ្នាំ២០១២), អាចមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2013/0I/Report-on-2011-womens-hearing_Phnom -Penh.pdf; Theresa De Langis, សវនាការរបស់ស្ត្រីនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកស្តីអពីអំពើហិង្សាយេនឌ័រនៅក្នុងជម្លោះ- សេចក្តីរាយការណ៍ពដំណើរការនៅក្នុងឆ្នាំ២០១២ (ខែធ្នូ ឆ្នាំ២០១២), អាចមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2013

ចំនួនអ្នកដែលចូលរួមសរុប មានប្រហែល១,០០០នាក់ ដែលមកពីមជ្ឈដ្ឋានផ្សេងៗពីគ្នា រួមមាន សិស្ស និស្សិត បុគ្គលិកមកពីអង្គការសង្គមស៊ីវិល មន្ត្រីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សមាជិកនៃអង្គការអន្តរជាតិ តំណាងម្ចាស់ជំនួយ និងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម បានចូលរួមសវនាការទាំងបីនោះ ។

ក្នុងអំឡុងពេលបីឆ្នាំនេះ អ្នកដែលនៅរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ចំនួនដប់ប្រាំបីនាក់ ព្រមទាំង សាក្សីជាច្រើនរូប បានមកផ្ដល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួនដែល ធ្លាប់បានឆ្លងកាត់អំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ផលប៉ះពាល់ ព្រមទាំងតម្រូវការ និងការទាមទារ ។ អ្នកទាំងនោះ គឺជាអ្នកចូលរួមដោយស្ម័គ្រចិត្ត និងបានផ្ដល់ការយល់ព្រមជាមុនសម្រាប់ដំណើរការ ទាំងមូល ។ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា សហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលដទៃផ្សេងទៀត ផ្ដល់ជំនួយដល់ពួកគាត់ដើម្បីរៀបចំការផ្ដល់សក្ខីកម្ម ផ្ដល់ការគាំទ្រផ្លូវចិត្តក្នុងដំណើរការទាំងមូល និងបន្ត តាមដានសុខុមាលភាពរបស់ពួកគាត់ ។ បន្ទាប់ពីមានវេទិកាស្ដាប់សំឡេងរបស់ស្ត្រី អ្នកដែលបានផ្ដល់ សក្ខីកម្មទាំងអស់បានរៀបរាប់ប្រាប់ថា គាត់បានទទួលផលប្រយោជន៍ ជាច្រើនពីការចូលរួមវេទិកានេះ ព្រោះគាត់មានអារម្មណ៍ថា ទទួលបានយុត្តិធម៌ មានភាពធូរស្បើយ បង្កើនភាពជិតស្និទ្ធជាមួយនឹងអ្នក ដែលនៅរស់រានមានជីវិតដទៃទៀត ។ ទាំងផ្ដល់សក្ខីកម្មមានការសប្បាយ និងពេញចិត្ត ដោយកត់ត្រា ទុកនូវបទពិសោធន៍របស់គាត់ ដើម្បីអនុញ្ញាតឲ្យក្មេងជំនាន់ក្រោយបាន ស្វែងយល់និងជៀសវាងកុំឲ្យ របបដែលគាបសង្កត់ទាំងនេះកើតឡើងជាថ្មីម្ដងទៀត ។

## ៣) ការស្ដាប់សំឡេងស្ត្រីជាយន្តការសម្រាប់យុត្តិធម៌អន្តកាល

យោងទៅតាមមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល ពាក្យថា“យុត្តិធម៌អន្តរកាល” គឺសំដៅទៅលើដំណើរការមួយដែលឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្ស ដែលមានលក្ខណៈជាសកល និងជាប្រព័ន្ធ កាលពីអតីតកាល ។[១៨] សេចក្ដីសម្រេចមួយត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០១១ ផ្ដោតទៅលើចំណុចសំខាន់មួយចំនួនទាក់ទងនឹងនឹងធាតុផ្សំ នៃយុត្តិធម៌អន្តរកាល ដោយដាក់បញ្ចូលនូវចំណុចបួន ៖ ការពិត យុត្តិធម៌ សំណង និង ការធានាមិន

/06/Women-Hearing-Report-2012-final-desgined-EN-small-5.pdf; បេនី យេ វេទិកាស្ដាប់សំឡេងស្ត្រី ជាមួយនឹងក្មេងជំនាន់ក្រោយស្ដីអំពីអំពើហិង្សាយេនឌ័រនៅក្នុងរបបខ្មែរក្រហម- សេចក្ដីរាយការណ៍ពីដំណើរការ (ខែឧសភា ឆ្នាំ២០១៤), អាចមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2014/05/WomenHearingEng.pdf.

[១៨] មើលអត្ថន័យនៅគេហទំព័រ http://ictj.org/about /transitional-justice.

ឲ្យមានហេតុការដូចនេះកើតឡើងម្តងទៀត ។[១៩] ដំណើរការនៃវេទិកាស្តាប់សំឡេងស្ត្រី បានដោះស្រាយនូវរាល់ធាតុផ្សំនីមួយៗ និងបានបំពេញមុខងារជាយន្តការយុត្តិធម៌អន្តរកាលមួយដ៏មានតម្លៃនៅក្នុងប្រទេសកម្ពុជា ។

## ៣.១ ធាតុផ្សំទាក់ទងនឹងការពិត

ធាតុផ្សំនៃ "ការពិត" ពាក់ព័ន្ធទៅនឹងការនិយាយការពិត មានន័យថាការផ្តល់ឱកាសសម្រាប់អ្នកនៅរស់រានមានជីវិត និងសាក្សី បានចែករំលែកពីបទពិសោធន៍របស់ពួកគាត់ ដោយអនុញ្ញាតឲ្យគាត់និយាយរឿងរ៉ាវតាមរបៀបផ្សេងៗគ្នា ។ ទាំងនោះក៏ទាក់ទងនឹង ការស្វែងរកការពិតផងដែរ មានន័យថា ការចងក្រងជាឯកសារ និងការយល់ដឹងអំពឧក្រិដ្ឋកម្មដែលកើតឡើងកាលពីអតីតកាល ព្រមទាំងយល់ដឹងអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មនោះ ។ តុលាការអន្តរជាតិ ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានខិតខំប្រឹងប្រែងដើម្បីបង្ហាញឲ្យឃើញនូវការពិត តាមរយៈដំណើរការដ៏តឹងរឹងមួយ ប្រកបដោយស្តង់ដារ អំពីការនិយាយការពិត និងការស្វែងរកការពិត ដោយទទួលយកទស្សនៈរបស់ជនជាប់ចោទយកមកពិចារណា ។ ដំណើរការកាត់ទោសដែលរៀបចំឡើងដោយស្ថាប័នតុលាការ គឺពិតជាមានលក្ខណៈចាំបាច់ក្រែងលែង នៅក្នុងប្រទេសដែលឧក្រិដ្ឋកម្មដ៏ប្រល័យទើបកើតឡើង ដើម្បីកត់ត្រានូវកំណត់ត្រាប្រវត្តិសាស្ត្រផ្លូវការមួយ ដែលអាចជួយតទល់ជាមួយអ្នកដែលបដិសេធមិនទទួលស្គាល់ថាមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរកើតឡើង ។[២០] ទោះបីជាយ៉ាងណា ដោយសារតែក្របខ័ណ្ឌច្បាប់មានលក្ខណៈតឹងរឹង ការនយាយអំពីសាច់រឿងតាមវិធីមួយចំនួនមិនត្រូវបានអនុញ្ញាត ឬមិនអាចប្រើប្រាស់បានដូចជានៅក្នុងវេទិកាស្តាប់សំឡេងស្ត្រីនេះទេ ។ ឧទាហរណ៍ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារហូតមកដល់បច្ចុប្បន្ន នៅក្នុងដីកាដំណោះស្រាយមិនទាន់បានដាក់បញ្ចូលបទល្មើសរំលោភដែលស្ថិតក្រោមបរិបទនៃការរៀបការដោយបង្ខំនៅឡើយទេ ។ សរុបមក ការទទួលខុសត្រូវចំពោះបទ

---

[១៩] សេចក់សម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធមនុស្សរបស់អង្គការសហប្រជាជាតិលេខ១៨/៧ របស់អ្នករាយការណ៍ពិសេសស្តីពីការជំរុញឲ្យមានការស្វែងរកការពិត យុត្តិធម៌ សំណង និងការធានាមិនឲ្យកើតមានឡើងវិញម្តងទៀត, កិច្ចប្រជុំលើទី១៨ ,U.N.Doc.A/HRC/18/2 (ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២) ។

[២០] សូមមើល, សមាគមអន្តរជាតិសម្រាប់គោលនយោបាយមនុស្សធម៌ និងការស្រាវជ្រាវអំពីជម្លោះ(aisbl), យុត្តិធម៌អន្តរកាល និងដំណើរការការកសាងសន្តិភាព, អាចរកមើលបានលើគេហទំព័រ www.peacebuildinginitiative.org/index0eea.html?pageId=I691 (៩,ឧសភា,២០១៤) ។

ល្មើសរំលោភ ដែលបានប្រព្រឹត្តនៅក្នុងបរិបទដទៃទៀតមិនត្រូវបាន លើកយកមកជំនុំជម្រះនៅក្នុងសវនាការទេ ។[២១]

ផ្ទុយមកវិញ វេទិកាស្តាប់សំឡេងស្ត្រី ជ្រើសរើសយកការនិយាយសាច់រឿងរបស់បុគ្គលម្នាក់ដោយដកស្រង់ចេញពីទស្សនៈរបស់ជនរងគ្រោះ ដែលពុំមានទស្សនៈលំអៀងចំពោះព្រឹត្តិការណ៍កាលពីអតីតកាល ។ ការចងចាំអំពីអំពើហិង្សាកាលពីអតីតកាល មានលក្ខណៈមិនផ្លូវការ និងស្រមើស្រមៃសាច់រឿង អាចងាយនឹងត្រូវបានបដិសេធ និងជំទាស់ចំពោះការរៀបរាប់សាច់រឿងទាំងនោះ ។ ប៉ុន្តែជាមួយនឹងវិធីសាស្ត្រប្រមូលផ្តុំជនរងគ្រោះ បានផ្តល់ជាសំឡេងកាន់ខ្លាំងទៅដល់អ្នកដែលនៅរស់រានមានជីវិតដែលងាយរងគ្រោះ និងជាញឹកញាប់ត្រូវបានដកចេញពីក្នុងដំណើរការសវនាការរបស់តុលាការ ។

នៅក្នុងបរិបទនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងអំឡុងពេលនៃវិវាទកម្ម ការនិយាយការពិត មិនថានៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ឬវេទិកាស្វែងរកការពិតទេ ចាំបាច់ត្រូវតែមានការពិចារណាអំពីហានិភ័យដែលកើតមានដោយការមាក់ងាយ និងការកើតឡើងវិញនូវជំងឺប៉ះពាល់ផ្លូវចិត្ត នៅពេលដែលពួកគាត់បង្ហាញអំពីបទពិសោធន៍នៃបទល្មើសផ្លូវភេទ ហើយយើងត្រូវតែប្រាកដថាអ្នកដែលចូលរួមដោយស្ម័គ្រចិត្ត ស្ថិតនៅក្នុងស្ថានភាពមួយដែលមានសុវត្ថិភាព ព្រមជាមួយការគាំពារគ្រប់គ្រាន់ពីសំណាក់អ្នកចិត្តវិទូ បុគ្គលិកសង្គមកិច្ច នងអ្នកផ្តល់សេវាផ្សេងៗទៀត ។

នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម បម្រាបជាប្រពៃណីជុំវិញអំពើហិង្សាផ្លូវភេទ នៅក្នុងសង្គមកម្ពុជាត្រូវបានពង្រឹង តាមរយៈជំនឿដែលជឿថាកមាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា មិនបានប្រព្រឹត្តបទល្មើសផ្លូវភេទ និងពង្រឹងវប្បធម៌ស្ងៀមស្ងាត់ដែលបង្កើតឡើងដោយរបបនោះ ។ ជនឿនេះអាចឲ្យយើងឃើញអំពីក្រមសីលធម៌របសបក្សកុម្មុយនីស្តកម្ពុជាដាក់ចំពោះកម្មាភិបាល ដែលបានចែងថា “អំពើអសីលធម៌” គឺជាបទល្មើសដែលត្រូវផ្តន្ទាទោស ។ ទោះជាយ៉ាងណាក្តី ការស្រាវជ្រាវថ្មីៗបានបង្ហាញថា ជាក់ស្តែងបទល្មើសផ្លូវភេទដែលប្រព្រឹត្តដោយកម្មាភិបាលខ្មែរក្រហម គឺមិនមែនជារឿងចម្លែកនោះទេ ប៉ុន្តែបទល្មើសទាំងនោះកម្រត្រូវបានគេលើកយកមកធ្វើការស៊ើបអង្កេត ហើយស្ទើរតែគ្មានការដាក់ទោសចំពោះឧក្រិដ្ឋជនទាំងនោះ រីឯជនរងគ្រោះពុំដែលទទួលបានការជួយឧបត្ថមមងណាឡើយ ។ ដោយសារតែអ្នកណាដែលប្រឆាំង ឬរិះគន់ចំពោះការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ អ្នកដែលរស់រានមានជីវិត និងសាក្សីមួយចំនួនតែងតែរក្សាភាពស្ងៀម

---

[២១] ឧបសគសម្រាប់ស្រ្តីដែលរស់រានមានជីវិតពីអំពើហិង្សាដែលទាក់ទងនឹងយេនឌ័របានចូលរួមដំណើរការរបស់តុលាការដើម្បីទាមទារសំណង ។ សូមមើល Carla Ferstman, Procedural and Substantive Obstacles to Reparations for Women Subjected to Violence through Judicial and Administrative Forums, Address at the Special Rapporteur on Violence Against Women’s Panel Discussion on Reparations for Women Subjected to Violence (៨,មិថុនា,២០១០), អាចមើលបានលើគេហទំព័រ www.redress.org/UNSRVW_July_2010.pdf.

ស្វាត់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកម្មាភិបាល ដើម្បីបានរួចផុតពីសេចក្តីស្លាប់ ។ នេះជាការបូកសរុបនៅក្នុងការស្រាវជ្រាវ ដោយការសម្ភាសន៍មតិជាមួយអ្នកផ្តល់ចម្លើយចំនួន១០៨នាក់ ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១១៖

> អ្នកផ្តល់ចម្លើយបានដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហមស្តីអំពី ការហាមឃាត់ **ការប្រព្រឹត្តខុសសីលធម៌** ហើយអ្នកផ្តល់ចម្លើយដទៃទៀតបានរៀបរាប់ថា ពួកគាត់បានឃើញការដាក់ទោសចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើអសីលធម៌ ។ អ្នកផ្តល់ចម្លើយបានរៀបរាប់ថា គោលនយោបាយនោះ នាំឲ្យជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ មួយចំនួនសុខចិត្តស្លាប់ ជាជាងប្រឈមមុខនឹងការដាក់ទោសដោយពួកខ្មែរក្រហម ដែលមានការពាក់ព័ន្ធជាមួយអំពើខុសសីលធម៌នោះ ។ បន្ថែមលើសពីនេះ អ្នកផ្តល់ចម្លើយបានរៀបរាប់ថា គោលនយោបាយប្រឆាំងនឹងអំពើអសីលធមបាននាំឲ្យអ្នកដែលបានប្រព្រឹត្តសម្លាប់ជនរងគ្រោះចោល សម្លាប់ខ្លួនឯង ឬក៏រត់គេចពីការដាក់ទោស ។ ទោះបីជា ប្រមាណ២០ភាគរយនៃអ្នកដែលបានផ្តល់ចម្លើយធ្លាប់បានចូលរួមនៅក្នុង "អង្គប្រជុំដើម្បីសម្រេច" ចំពោះអំពើខុសសីលធម៌ ឬធ្លាប់បានឃើញការដាក់ទោសចំពោះអំពើខុសសីលធម៌ដែលបានប្រព្រឹត្ត ប៉ុន្តែមានករណីតែបប៉ុណ្ណោះដែលត្រូវបានរាយការណ៍ថា បុគ្គលដែលត្រូវបានដាក់ទោស មានជាប់ពន្ធ័នឹងទំនាក់ទំនងដែលការព្រមព្រៀងគ្នា ។ ហើយមានតែមួយករណីប៉ុណ្ណោះ ដែលជនដៃដល់ត្រូវបាននាំយកទៅដាក់ទោស ។[២២]

កត្តាទាំងនោះធ្វើមានការរាំងស្ទះសម្រាប់ស្ត្រីដើម្បីបន្តដំណើរឆ្ពោះទៅមុខ និងស្វែងរកនូវការគាំទ្រសម្រាប់ខ្លួន ។

វេទិកាស្តាប់សំឡេងស្ត្រីបានផ្តល់សារសំខាន់ចំពោះអ្នកដែលនៅរស់រានមានជីវិតពបទអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ រួមជាមួយនឹងការគាំទ្រសម្រាប់ជម្នះនូវរាល់ឧបសគ្គ និងភាពស្ងៀមស្ងាត់របស់គាត់ដែលមានក្នុងរយៈពេលជិតមួយទសវត្សរ៍ ។ សម្រាប់អ្នកដែលបានចូលរួមក្នុងការផ្តល់សក្ខីកម្មវេទិកាស្តាប់សំឡេងស្ត្រីបានបង្កើតឱកាសជាលើកដំបូងសម្រាប់ពួកគាត់ ដើម្បីនិយាយអំពីបទពិសោធន៍របស់ខ្លួនដែលធ្លាប់បានឆ្លងកាត់អំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ។ មនុស្សជាច្រើនបានលើកឡើងថា ការបកស្រាយនូវការពិតជាសាធារណៈ ជាពិសេសនៅចំពោះមុខក្មេងជំនាន់ក្រោយ គឺជាការកិច្ចការសំខាន់មួយក្នុងចំណោមកិច្ចការសំខាន់ៗជាច្រើនផ្សេងទៀតដែលអាចជួយលើកទឹកចិត្តឲ្យមានការចូលរួម

---

[២២] Natale, សូមមើលកំណត់សម្គាល់ជើងទំព័រទី៣ខាងលើ ។ ទំព័រទី២ ។

នៅក្នុងវេទិកាស្តាប់សំឡេងស្ត្រី ។ សក្ខីកម្មរបស់អ្នកទាំងនោះ ត្រូវបានកត់ត្រា និងចងក្រងទុក តាមរយៈការបោះពុម្ព និងថតជាខ្សែភាពយន្ត ដើម្បីចូលរួមនៅក្នុងការកត់ត្រាទុកជាប្រវត្តិសាស្ត្រ និងដើម្បីឲ្យលើកស្ទួយឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីផលប៉ះពាល់នៅជុំវិញអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ដែលវិធីសាស្ត្រទាំងពីរនេះ គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ការយល់ដឹងក្នុងកិច្ចពិភាក្សាអំពីអតីតកាល ។

## ៣.២ ធាតុផ្សំទាក់ទងនឹងយុត្តិធម៌

"យុត្តិធម៌" សំដៅទៅលើយុត្តិធម៌ព្រហ្មទណ្ឌ មានន័យថា ការស៊ើបអង្កេតរបស់តុលាការ ឬការចោទប្រកាន់ និងមានការរកឃើញថាមានកហុស ឬការផ្តន្ទាទោសបុគ្គលណាម្នាក់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋអ្វីមួយ ។ ជាមួយនឹងការបង្កើតតុលាការអន្តរជាតិ ឬតុលាការពិសេសនៅតាមបណ្តាប្រទេសក្រោយជម្លោះនៅទូទាំងពិភពលោក ដើម្បីដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរកាលពីអតីតកាល គឺជាទស្សនវិស័យនៃយុត្តិធម៌អន្តរកាលដែលទទួលបានការចាប់អារម្មណ៍ជាច្រើន ។

ចំណែកឯតុលាការ ក៏ត្រូវធានាឲ្យបាននូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលជាសិទ្ធិចាំបាច់របស់ជនជាប់ចោទ ។ សម្រាប់វេទិកាស្តាប់សំឡេងរបស់ស្ត្រី អាចជាយន្តការសំខាន់សម្រាប់ជនរងគ្រោះ ពីព្រោះវេទិកានេះមិនបានកំណត់ពីការទទួលខុសត្រូវរបស់បុគ្គលណាម្នាក់សម្រាប់បទល្មើសនីមួយៗ ឬក៏ការដាក់ទណ្ឌកម្មចំពោះជនដែលដល់នោះទេ ។ យ៉ាងណាក៏ដោយ សំណួរទាក់ទងនឹងគោលការណ៍នៃការសន្មតថាគ្មានទោស ដរាបណាមិនរកឃើញថាមានទោស ត្រូវបានលើកឡើងនៅក្នុងវេទិកាស្តាប់សំឡេងស្ត្រីជាពិសេសនៅក្នុងករណីមួយចំនួននៅពេលដែលអ្នកផ្តល់សក្ខីកម្មបានស្គាល់បុគ្គលដែលត្រូវបានចោទប្រកាន់ថាជាអ្នកដែលបានធ្វើឲ្យគាត់ទទួលរងព្យសនកម្ម ។ ដើម្បីជៀសវាងការរំលោភលើគោលការណ៍នៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ បុគលដែលផ្តល់សក្ខីកម្មបានយល់ព្រមមិនបង្ហាញពីអត្តសញ្ញាណដែដល់នៅអំឡុងពេលនៃការផ្តល់សក្ខីកម្ម ។ ជនរងគ្រោះទាំងអស់ត្រូវតែយល់ព្រមចំពោះលក្ខខណ្ឌនេះដោយគ្មានភាពតានតឹង ឬក៏ការព្រួយបារម្ភអ្វីទាំងអស់ ។ នៅក្នុងករណីភាគច្រើនជនរងគ្រោះមិនបានស្គាល់ជនដែលប្រព្រឹត្តល្មើសនោះទេ ។ មានករណីមួយ អ្នកដែលបានមកផ្តល់សក្ខីកម្មបានឃើញផ្ទាល់ភ្នែកនូវព្រឹត្តិការណ៍ចាប់រំលោភបូក និងការសម្លាប់បងប្អូនស្រីរបស់គាត់ ដែលកម្មាភិបាលខ្មែរក្រហមនោះនៅតែបន្តមានវត្តមានរស់នៅក្នុងភូមិរបស់គាត់រហូតសព្វថ្ងៃ តែគាត់មិនអាចលាតត្រដាងពីអត្តសញ្ញាណរបស់ជនល្មើសនោះបានទេ ព្រោះដើម្បីការពារខ្លួនរបស់គាត់ ។

ការសួរដេញដាលសាក្សី អាចនឹងធ្វើឲ្យកាន់តែមានភាពតានតឹងសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសអ្នកដែលទទួលរងនៅក្នុងករណីនៃអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដែលមិនមានដូចនៅក្នុងវេទិកាស្តាប់សំឡេងស្ត្រី ។ ដើម្បីកាត់បន្ថយភាពតានតឹង បុគ្គលដែលផ្តល់សក្ខីកម្ម

គឺត្រូវបានណែនាំតាមរយៈសំណួរដែលត្រូវបានសួរដោយមនុស្សតែម្នាក់ ដែលបានជួយគាត់ក្នុងការផ្ដល់សក្ខីកម្ម ។ អ្នកចូលរួមទាំងអស់បានរៀបរាប់ថា ពួកគាត់មានភាពភ័យខ្លាច និងមានការព្រួយបារម្ភ នៅពេលដែលគាត់និយាយ "ខុស" ប៉ុន្តែគាត់មានភាពធូរស្បើយ នៅពេលមានវត្តមានរបស់មនុស្ស ដែលគាត់ទុកចិត្តផ្ដល់ជាសំណួរខ្លះៗ ដើម្បីជាការណែនាំ ។

វេទិកាស្ដាប់សំឡេងស្ត្រីមិនអាចបំពេញតួនាទីជាតុលាការពេញលេញបានទេ ។ ប៉ុន្តែ អ្នកដែលចូលមកផ្ដល់សក្ខីកម្មនៅវេទិកានេះ បានបង្ហាញពីអត្ថន័យនៃយុត្តិធម និងការបំពេញសេចក្ដីពេញចិត្ត ដែលទទួលស្គាល់ជាសាធារណៈពីក្រុមគណៈវិនិច្ឆ័យ អ្នកគាំទ្រការប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ និង បញ្ហាយេនឌ័រ និងការទទួលរងការឈឺចាប់របស់គាត់ ។ បន្ទាប់ពីការផ្ដល់សក្ខីកម្មរួច សមាជិកនៃគណៈវិនិច្ឆ័យនឹងជួយដោះស្រាយបញ្ហារបស់អ្នកផ្ដល់សក្ខីកម្មម្ដងម្នាក់ៗ ដែលបានបង្ហាញពីបញ្ហា ការវាយតម្លៃ និងការលើកទឹកចិត្តសម្រាប់អ្នកដែលបានចូលរួមនៅក្នុងវេទិកានោះ ។ តាមរយៈសេចក្ដីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ អ្នកទាំងនោះបានទទួលសាល់បទពិសោធន៍ចូលរួមជាសាធារណៈ និងការថ្កោលទោសចំពោះការរំលោភបំពានដែលបានប្រព្រឹត្តទៅលើរូបគាត់ ។

ការបំភ្លឺអំពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ថាជាការរំលោភសិទ្ធិមនុស្ស និងជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺមានសារសំខាន់ ជាពិសេសសម្រាប់អ្នកដែលរស់រានមានជីវិត ព្រោះវាហាក់បីដូចជាបានផ្លាស់ប្ដូរការស្ដីបន្ទោស និងភាពអាម៉ាស់ ដែលធ្លាប់មាននៅលើជនរងគ្រោះ តែត្រូវធ្លាក់ទៅលើជនល្មើសទៅវិញ ។ វេទិកាស្ដាប់សំឡេងរបស់ស្ត្រី ទោះបីជាវាពុំអាចជំនួសឲ្យការកាត់ទោសតាមរយៈតុលាការក៏ដោយ តែមានការជឿជាក់ក្នុងការស្វែងរកយុត្តិធម៌ ដែលជាប់ជាមួយយុត្តិធម៌ព្រហ្មទណ្ឌ និងមានតម្លៃសម្រាប់អ្នកដែលនៅរស់រានមានជីវិត ។

## ៣.៣ ធាតុផ្សំទាក់ទងនឹងសំណង

នៅក្នុងបរិបទនៃដំណើរការយុត្តិធម៌អន្តរកាល ធាតុផ្សំទាក់ទងនឹងសំណង ត្រូវបានយល់បានថាជាទម្រង់ផ្សេងៗគ្នាដែលរដ្ឋត្រូវទទួលបន្ទុកសង សម្រាប់ការរំលោភសិទ្ធិមនុស្សជារួមដោយរដ ដែលបានកំណត់នៅក្នុង គោលការណ៍ជាមូលដ្ឋាន និងសេចក្ដីណែនាំស្ដីពីសិទ្ធិទទួលបានសំណងសម្រាប់ជនរងគ្រោះពីការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ[២៣] (គោលការណ៍ជាមូលដ្ឋាន) ។ បើប្រៀបធៀប នៅក្នុងអង្គជំនុំជម្រះ វិសាមញ្ញនៅក្នុងតុលាការកម្ពុជា ជនរងគ្រោះត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការសវនាការ ប៉ុន្តែគាត់មានសិទ្ធិទទួលបានត្រឹមតែសំណងដែលមានលក្ខណៈសមូហភាព និងសំណង ជាការផ្សះផ្សារបួសផ្លូវចិត្ត

[២៣] អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ចុះនៅថ្ងៃទី២១ ខែមនា ឆ្នាំ២០០៦ ។

ប៉ុណ្ណោះ នៅពេលដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធចំពោះបទឧក្រិដ្ឋដែលបានបង្កព្យសនកម្មដល់ជនរងគ្រោះ ។[២៤] ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាមានសិទ្ធិអំណាចតិចជាងទម្រង់ដែលត្រូវបានទទួលស្គាល់នៅក្នុងគោលការណ៍ជាមូលដ្ឋាននៅក្នុងការផ្តល់សំណង ដូច្នេះហើយតុលាការមិនអាចផ្តល់សំណងជាទឹកប្រាក់សម្រាប់បុគ្គលម្នាក់ៗបានឡើយ ។ មួយវិញទៀត អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាធ្លាប់បានសម្រេចថា តុលាការមិនអាចផ្តល់សំណងប្រឆាំងទៅនឹងរដ្ឋាភិបាល[២៥] បានឡើយ ប៉ុន្តែគោលការណ៍ជាមូលដ្ឋានទាក់ទងនឹងសំណងបានចែងថា រដ្ឋមានកាតព្វកិច្ចត្រូវផ្តល់សំណង ។

វេទិកាស្តាប់សំឡេងស្ត្រី បានផ្តល់ជាទម្រង់បន្ថែមសម្រាប់ដោះស្រាយ ដើម្បីរួមចំណែកដល់ការស្តារឡើងវិញ និងបំពេញឡើងវិញពីការខូតខាត ។ មនុស្សទាំងអស់ដែលបានផ្តល់សក្ខីកម្មនៅក្នុងវេទិកានេះ ទទួលបានការថែទាំខាងផ្លូវចិត្តទាំងមុន អំឡុងពេល និងបន្ទាប់ពីការចូលរួមរបស់គាត់ ដែលបានជួយជំរុញលើកទឹកចិត្តរបស់គាត់ឲ្យជាសះស្បើយពីរបួសផ្លូវចិត្ត ។ មនុស្សម្នាក់ដែលបានផ្តល់សក្ខីកម្មនៅក្នុងវេទិកាស្តាប់សំឡេងស្ត្រីថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកនៅក្នុងឆ្នាំ២០១២ បានបង្ហាញពីយោបល់របស់ខ្លួនថា «ខណៈពេលដែលរឿងរ៉ាវរបស់ពួកគាត់ត្រូវបានចែករំលែកជាសាធារណៈ ពួកគាត់មានអារម្មណ៍ថា វាពិតជាលំបាកនៅក្នុងចិត្ត ហើយពួកគាត់មានអារម្មណ៍មួយទៀតថា ចាប់ផ្តើមមានភាពរឹងមាំ និងធូរស្រាលផ្លូវអារម្មណ៍ បនាបពីបានចូលរួមក្នុងវេទិកានេះ»[២៦] ដូចគ្នានេះដែរនៅក្នុងឆ្នាំ ២០១៣:

> ក្រុមស្រ់បាននិយាយថា មុនពេលដែលគាត់ផល់សក្ខីកម្ម គាត់មានអារម្មណ៍ថាអស់សង្ឃឹម និងតូចចិត្តជាពន់ពេក ដោយសារតែកាលពីមុនគាត់មិនមានឱកាសបានចូលរួមដើម្បីមកបកស្រាយអំពីអំពើហិង្សា ដែលគាត់បានទទួលរង ។ គាត់មានអារម្មណ៍សប្បាយរីករាយ ដែលបាននិយាយនៅពីមុខសាធារណជនជាលើកដំបូង ។ បន្ទាប់ពីការចូលរួមនៅកងវេទិកាស្តាប់សំឡេងស្ត្រីមនុស្សបួននាក់សំដែងនូវការធូរស្បើយក្នុងអារម្មណ៍

[២៤] មើលវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. វិសោធនកម្មលើកទី៨, ការពិនិត្យឡើងវិញនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១, វិធាន ២៣ កថាខណ្ឌទី១(ខ) និង២៣ស្ទួនបួន កថាខណ្ឌ១ ។

[២៥] សូមមើល សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ដូចកណត់សម្គាល់ជើងទំព័រទី៤ខាងលើ, កថាខណ្ឌ៦៧១ ។ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល, សំណុំរឿង០០១, Case No. 001/18-07-2007-ECCC/SC, កថាខណ្ឌ ៦៦២-៦៦៥, (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) ។

[២៦] De Langis, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ខាងលើ ។ ទំព័រ៣១ ។

និងទទួលបានការគាំទ្រពីទស្សនិកជន ជាពិសេសនៅពេលដែលគាត់បានឃើញទស្សនិកជនយំព្រោះតែមានអារម្មណ៍អាណិតគាត។[២៧]

អ្នកដែលរស់រានមានជីវិតមួយចំនួន ដែលបានលាតត្រដាងអំពីបទពិសោធន៍ផ្ទាល់ខ្លួនជាលើកដំបូងអំពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ អាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីការធ្វើអន្តរាគមន៍ជាពិសេសចំពោះករណីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដូចជាក្រុមស្ត្រីជួយខ្លួនឯងជាដើម។[២៨] យោងទៅតាមគោលការណ៍ជាមូលដ្ឋាន ការសងសំណងការខូចខាតគួរតែរួមបញ្ចូលការទទួលស្គាល់ការពិត និងការទទួលខុសត្រូវចំពោះការរំលោភបំពាននានា។ ចំណុចទាំងពីរនោះត្រូវបានដោះស្រាយដោយវេទិកាស្តាប់សំឡេងស្ត្រី ដូចបានរៀបរាប់ខាងលើនៅក្រោមធាតុផ្សំនៃការពិត និងយុត្តិធម៌។

ដោយសារគំនិតផ្តួចផ្តើមធ្វើឡើងដោយសង្គមស៊ីវិល និងមានលក្ខណៈឯករាជ្យពីកិច្ចដំណើរការផ្លូវការរបស់តុលាការ វេទិកាស្តាប់សំឡេងស្ត្រីមិនអាចផ្តល់សំណង ដូចដែលមានកំណត់នៅក្នុងគោលការណ៍ជាមូលដ្ឋាន ឬវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅកងតុលាការកម្ពុជាឡើយ។ ទោះជាយ៉ាងណាក វេទិកាស្តាប់សំឡេងស្ត្រីអាចជាវេទិកាគំរូសម្រាប់សំណងដែលរៀបចំដោយអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ឬអាចទទួលយកដោយរាជរដ្ឋាភិបាល បិរបទនៃកម្មវិធីសំណងទូទៅមួយ។ សក្ខីកម្មរបស់ជនរងគ្រោះទាក់ទងទៅនឹងតម្រូវការ និងការស្នើសុំ យ៉ាងហោចណាស់ត្រូវបានកត់ត្រាទុកនៅក្នុងអំឡុងពេលនៃវេទិកាស្តាប់សំឡេងស្ត្រីនេះ។ ប្រធានបទសំខាន់ដែលកំពុងតែអនុវត្ត គឺការកត់ត្រាទុកនូវបទពិសោធន៍របស់ស្ត្រីជាជនរងគ្រោះសម្រាប់ក្មេងជំនាន់ក្រោយសិក្សារៀនសូត្រ និងទប់ស្កាត់អំពើហិង្សាដែលប្រឆាំងលើស្ត្រីនាថ្ងៃអនាគត។ ការស្នើសុំរបស់ស្ត្រីជាជនរងគ្រោះអាចនឹងត្រូវប្រើជាមូលដ្ឋានសម្រាប់កម្មវិធីសំណងដែលបញ្ចូលទៅក្នុងការអប់រំមួយ និងការគាំទ្រដល់ការទប់ស្កាត់អំពើហិង្សា និងបញ្ហាយេនឌ័រ។ ការស្នើសុំមួយទៀត គឺការអំពាវនាវឲ្យបញ្ចប់ការរើសអើងប្រឆាំងនឹងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទដែលអាច ជាគ្រឹះសម្រាប់កម្មវិធីសំណងដែលជួយលើកស្ទួយការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថ។

## ៣.៤ ធាតុផ្សំដែលធានាមិនឲ្យមានអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត

---

[២៧] បនើ យេ, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ខាងលើ។

[២៨] ក្រុមអ្នកជួយខ្លួនឯងបានប្រមូលផ្តុំអ្នកដែលរស់រានមានជីវិតពី៨ ទៅ១០រូប ត្រូវបានទទួលការណែនាំពីអ្នកចិត្តវិទ្យាតាមរយៈកិច្ចប្រជុំពី៧ ទៅ៨ដង ដែលអនុញ្ញាតឲ្យគាត់អាចសិក្សារៀនសូត្រពីវិធីដោះស្រាយជាមួយនឹងបទពិសោធន៍នៃអំពើហិង្សាកាលពីអតីតកាល និងការគាំទ្រគ្នាទៅវិញទៅមក។ របាយការណ៍ស្តីពីផលប៉ះពាល់នៃក្រុមអ្នកជួយខ្លួនឯង គឺសម្រាប់អ្នកដែលរស់រានមានជីវិតពីការរៀបការដោយបង្ខំ។ សូមមើល ឃឹម សុធារី, អតីត និងបច្ចុប្បន្ន នៃអ្នកដែលរស់រានមានជីវិតនៃការរៀបការដោយបង្ខំ (ខែមិថុនា ឆ្នាំ២០១២), អាចរកមើលបានលើគេហទំព័រ http://gbvkr.org/wp-content/uploads/2013/04/The-Past-and -the-Present-of-forced-Marriage-Survivors-small-2.pdf.

ធាតុផ្សំដែលធានាមិនឲ្យមានអំពើបែបនេះកើតឡើងជាថ្មីម្តងទៀត ជាចំណុចទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងកំណែទម្រង់វិស័យសន្តិសុខ និងច្បាប់ ដើម្បីទប់ស្កាត់អំពើហិង្សាឲ្យបានកាន់តែទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធនាពេលអនាគត ។ ក្នុងនាមជាហត្ថលេខីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចត្រូវលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។ នៅក្នុងការអនុវត្តជាក់ស្តែង អំពើហិង្សានៅក្នុងរដ្ឋមួយនៅតែមានជាទូទៅ ហើយការប្រើប្រាស់អំពើហិង្សាដ៏សាហាវនោះ គឺធ្វើឡើងដើម្បីប្រឆាំងនឹងអ្នកតវ៉ាស៊ីវិល ។[២៩]

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាត្រូវបានមើលឃើញថា ជាសាលាក្តីមួយដែលមានបំណងចង់បង្កើតមូលដ្ឋានសម្រាប់កំណែទម្រង់ប្រព័ន្ធតុលាការ តាមរយៈការអនុវត្តត្រឹមត្រូវតាមនីតិវិធី ដើម្បីធ្វើជាតុលាការគំរូសម្រាប់តុលាការជាតិ ។ គម្រោងមួយចំនួនដែលកំពុងត្រូវបានអនុវត្ត គឺធ្វើឡើងក្នុងគោលបំណងដើម្បីចែករំលែកមេរៀនដែលបានសិក្សាទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងគោលការណ៍នៃនីតិរដ្ឋ ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅក្នុងប្រទេសកម្ពុជា បាននាំមុខនៅក្នុងវិស័យនេះតាមរយៈការរៀបចំកិច្ចប្រជុំតុមូលជាមួយនឹងព្រះរាជអាជ្ញា និងចៅក្រមកម្ពុជា ។[៣០] ក្នុងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាសានគ្រប់គ្រងបូព៌ាបស្ចិម ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានចេញផ្សាយសេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយប្រើប្រាស់សេចក្តីសម្រេចផ្នែកនីតិវិធីរបស់អង្គជុំនំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលមានពាក់ព័ន្ធនឹងមាត្រានានាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។[៣១]

---

[២៩] សូមមើល, ស៊ាន គេហាន, ម៉ម គន្ធា & សុភ័ក្រ្ត ចត្រីយ៉ា, Strikers, Police-Clash, ភ្នំពេញប៉ុស, ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ។ អាចរកមើលបានលើគេហទំព័រ www.phnompenhpost.com/national/strikers-police-clash; ជាង សុខា, ស៊ាន គេហាន & Shane Worell, *Crackdown Turns Deadly*, ភ្នំពេញប៉ុស្ត, ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ អាចមើលបានលើគេហទំព័រ www.phnompenhpost.com/national/crackdown-turns-deadly (ពណ៌នាពីហេតុការណ៍ពីរដែលបានកើតឡើង) ។

[៣០] សូមមើល ព័ត៌មានបន្ថែមនៅលើគម្រោងរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, កិច្ចប្រជុំលើកទី៥របស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា- រៀបចំដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣) (ឯកសារនេះមាននៅជាមួយអ្នកនិពន្ធ) ។

[៣១] សេចក្តីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ៖ ការពន្យល់ទៅអង្គជុំនំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងជម្រើសសម្រាប់យុត្តិសាស្រ្តអន្តរជាតិ (ខែមនា ឆ្នាំ២០១៤), អាចមើលបានលើគេហទំព័រ http://cambodia.ohchr.org/WebDOCs/DocProgrammes/Annotated_Cambodian_Code_of_Criminal_Procedure_Eng.pdf.

វេទិកាស្តាប់សំឡេងស្ត្រីទាំងបីលើកបានចេញសេចក្តីថ្លែងការណ៍ រួមជាមួយនឹងអនុសាសន៍ទាក់ទងនឹងគោលនយោបាយដាក់ជូនទៅរាជរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធផ្សេងទៀត ។ភាគច្រើននៃអ្នកទាំងនោះបានរៀបរាប់អំពីវិធានការដាក់លាក់ ដែលចាំបាច់ដើម្បីទប់ស្កាត់អំពើហិង្សាផ្សេងទៀតនាពេលអនាគត ជាពិសេសអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ និងដោះស្រាយឫសគល់ដើមនៃការរើសអើងភេទ ។

នៅក្នុងឆ្នាំ២០១១ នៅក្នុងចំណោមវិធានការផ្សេងៗទៀត ក្រុមវ៉ាគ្គិនបានផ្តល់អនុសាសន៍ទៅរាជរដ្ឋាភិបាលកម្ពុជាថា គួរជំរុញឲ្យមានលើកស្ទួយការយល់ដឹងជាសាធារណៈ និងបញ្ចូលទៅក្នុងកម្មវិធីសិក្សាអប់រំនៅក្នុងសាលារៀនដើម្បីលុបបំបាត់ជំនឿដែលនៅជុំវិញអំពើហិង្សាផ្លូវភេទ ។ អនុសាសន៍សម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា រួមមានការបង្កើតឲ្យមានអ្នកជំនាញជាន់ខ្ពស់ផ្នែកយេនឌ័រ ដោយសហការជាមួយសមភាគីជាតិ ដើម្បីតស៊ូមតិឲ្យមានការដាក់បញ្ចូលនូវការផ្សព្វផ្សាយទស្សនៈអំពីយេនឌ័រ និងការយកចិត្តទុកដាក់នឹងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ហើយចាំបាច់ត្រូវធានាថា រឿងទាំងនេះ គឺជាផ្នែកមួយរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងច្បាប់ជាតិ ។ មានការអំពាវនាវឲ្យសង្គមស៊ីវិលជួយលើកកម្ពស់សិទ្ធិអំណាច និងប្រមូលផ្តុំអ្នកដែលរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ដោយការរក្សា និងការកសាងបណ្តាញនៃអ្នកដែលរស់រានមានជីវិត និងការគាំទ្រដល់ការពិភាក្សារបស់គាត់ ។[៣២]

នៅក្នុងឆ្នាំ២០១២ ក្រុមវ៉ាគ្គិនបានផ្តល់នូវអនុសាសន៍សម្រាប់បណ្តាប្រទេសនីមួយៗដែលបានចូលរួម ។ សម្រាប់កម្ពុជា អនុសាសន៍ដែលផ្តល់ទៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានស្នើឲ្យបញ្រាបសំណួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ នៅក្នុងការចោទប្រកាន់ផ្សេងទៀតសម្រាប់សំណុំរឿង០០៣ និង០០៤ ។ ក្រុមវ៉ាគ្គិនបានស្នើសុំឲ្យរាជរដ្ឋាភិបាលឲ្យចូលរួមគាំទ្រឯកសារជាប្រវត្តិសាស្ត្រ និងបទពិសោធនកាលពីអតីតកាលរបស់ជនរងគ្រោះ និងអ្នករសរានមានជីវិតដើម្បីបំបែកភាពស្ងៀមស្ងាត់របស់គាត់ក្នុងការជួយព្យាបាលរបួសផ្លូវចិត្ត ។[៣៣]

នៅកងឆ្នាំ ២០១៣ វ៉ាគ្គិនដែលជាក្រុមនិស្សិតបានបង្ហាញអំពីដំណោះស្រាយទៅមិត្តភក្តិរបស់ខ្លួនដោយអំពាវនាវដល់យុវជនឲ្យចូលរួមក្នុងសកម្មភាពដោះស្រាយអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដូចជា កម្មវិធីបណ្តុះបណ្តាល វេទិកាសាធារណៈ សិក្ខាសាលា និងដំណើរទស្សនកិច្ចសិក្សាផ្សេងៗទៀត ដើម្បីចែករំលែកពត៌មាន ចំណេះដឹង ក្នុងគោលបំណងដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីលបបំបាត់ការរើសអើងដែលប្រឆាំងនឹងជនរងគ្រោះ ដើម្បីកំណត់មិនឲ្យប្រព្រឹត្ត

---

[៣២] សូមមើល, គម្រោងការការពារសិទ្ធិកម្ពុជា, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលើ ។ ទំព័រ១៦ដល់១៨ ។

[៣៣] សូមមើល De Langis, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលើ ។ ទំព័រ៥៥ដល់៥៦ ។

ទម្រង់នៃអំពើហិង្សាយេនឌ័រណាមួយ និងដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋ ជាពិសេសក្រុមគ្រួសារ និងមិត្តភក្តិដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងផ្នែកយេនឌ័រ ។[៣៨]

សេចក្តីថ្លែងការណ៍មួយរបស់វ៉ាគ្និន គឺផ្អែកលើការរកឃើញតាមរយៈការផ្តល់សក្ខីកម្មរបស់អ្នកចូលរួម និងពិនិត្យឯកសារឡើងវិញដោយអ្នកជំនាញផ្នែកច្បាប់ និងផ្នែកយេនឌ័រ ។ សេចក្តីថ្លែងការណ៍របស់ក្រុមវ៉ាគ្និនត្រូវបានព្រាងដោយប្រុងប្រយ័ត្ន ហើយសេចក្តីថ្លែងការណ៍នោះ គឺជាធនធានដ៏មានតម្លៃសម្រាប់រាជរដ្ឋាភិបាល និងអាចផ្តល់នូវការណែនាំសម្រាប់ការអនុវត្ត និងសម្រាប់ការធានាមិនឲ្យកើតមានឡើងវិញម្តងទៀត ។ ខុសប្លែកពីកម្មវិធីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែលផ្តោតតែទៅលើគោលដៅទាក់ទងនឹងច្បាប់ និងមានការផ្តោតតិចតួចនៅឡើយពាក់ព័ន្ធនឹងការផ្ទេរចំណេះដឹងផ្នែកច្បាប់ សេចក្តីថ្លែងការណ៍របស់វ៉ាគ្និននៅក្នុងវេទិកាស្តាប់សំឡេងស្ត្រីបានជ្រើសយកវិធីសាស្ត្រកម្រិតគោលនយោបាយ ដើម្បីធ្វើការផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ធំនេះ ។

នៅក្នុងឆ្នាំ២០១១ ក្រុមវ៉ាគ្និនបានស្នើសុំរាជរដ្ឋាភិបាលកម្ពុជាបង្កើតមូលនិធិថ្នាក់ជាតិមួយសម្រាប់ផ្តល់សំណងជូនជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ។ លើសពីនេះទៅទៀត ក្នុងមានជាប្រធាននៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ នៅកងឆ្នាំ២០១២ រាជរដ្ឋាភិបាលត្រូវបានស្នើសុំឲ្យធ្វើជាអធិបតីភាពនៅក្នុងអំឡុងពេលនៃការបើកសម្ពោធវិទ្យាស្ថានសន្តិភាព និងការផ្សះផ្សា ដើម្បីជាការលើកកម្ពស់ទស្សនៈរឹងមាំផ្នែកយេនឌ័រនៅក្នុងវិទ្យាស្ថាននេះ និងធានាបានថា បញ្ហារបស់ស្ត្រី រួមមានបញ្ហាសន្តិភាព និងសន្តិសុខ បញ្ហាឧក្រិដ្ឋកម្មផ្លូវភេទទាក់ទងនឹងវិវាទកម ត្រូវបានដោះស្រាយសម្រាប់តំបន់អាស៊ានទាំងមូល និងរក្សាបាននូវភាពជាអ្នកដឹកនាំលើបញ្ហាទាំងនោះក្នុងឋានៈជាសមាជិកមួយរបស់អាស៊ាន ។[៣៩]

នៅក្នុងឆ្នាំ ២០១២ ក្រុមវ៉ាគ្និនបានផ្តល់អនុសាសន៍ទាក់ទងនឹងការអភិវឌ្ឍយន្តការក្រៅប្រព័ន្ធតុលាការ និងការកសាងសន្តិភាព ដើម្បីផ្តល់ឱកាសជូនជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រ និងធ្វើឲ្យសំឡេងរបស់គាត់ត្រូវបានផ្សព្វផ្សាយ និងបើកឲ្យទទួលស្គាល់ជាសាធារណៈសម្រាប់កិច្ចសន្ទនាស្តីពីបញ្ហានៃអំពើហិង្សាយេនឌ័រ ។ ក្រុមវ៉ាគ្និនបានស្នើសុំរាជរដ្ឋាភិបាលឲ្យបង្កើតផែនការសកម្មភាពថ្នាក់ជាតិមួយសម្រាប់អនុវត្តចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិលេខ ១៣២៥ និងលេខ១៨២០ ដោយផ្តោតទៅលើស្ត្រី សន្តិភាព និងសន្តិសុខ ដោយសហការជាមួយ

---

[៣៨] សូមមើល, បេនី យេ, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលើ ។

[៣៩] សូមមើល, គម្រោងការការពារសិទ្ធិកម្ពុជា, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលើ ។ ទំព័រ១៧ ។

អង្គការមិនមែនរាជរដ្ឋាភិបាលដែលធ្វើការផ្តោតលើសិទ្ធិស្ត្រី និងសិទ្ធិមនុស្ស ដោយមានបន្ទាញអំពីពេលវេលាច្បាស់លាស់ និងធនធានគ្រប់គ្រាន់ ។[៣៦]

នៅក្នុងឆ្នាំ២០១៣ វាគ្មិនដែលជាក្រុមនិស្សិតបានស្នើសុំឲ្យដាក់បញ្ចូលបញ្ហាអំពើហិង្សាយេនឌ័រ (ទាំងក្នុងអឡុងពេលនៃរបបខ្មែរក្រហម និងពេលបច្ចុប្បន្ន) ទៅក្នុងកម្មវិធីសិក្សានៃថ្នាក់អនុវិទ្យាល័យ និងមហាវិទ្យាល័យនានា ។[៣៧]

## ៤) ការស្តាប់សំឡេងស្ត្រីជាយន្តការបំពេញបន្ថែមសម្រាប់តុលាការ និងជាគណៈកម្មការការស្វែងរកការពិត

វេទិកាស្តាប់សំឡេងស្ត្រីនៅក្នុងទម្រង់ដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជា មានលក្ខណៈខុសពីប្លែកពីគណៈកម្មការស្វែងរកការពិត ព្រោះវេទិកានេះមិនមែនបង្កើតឡើងដោយរដ្ឋ ហើយគោលបំណងដ៏សំខាន់របស់វេទិកានេះ គឺដើម្បីផ្តល់សំឡេងសម្រាប់អ្នកដែលរស់រានមានជីវិតដែលរួចផុតពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ។ យោងតាមមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល គណៈកម្មការស្វែងរកការពិតមិនមែនជាស្ថាប័នតុលាការទេ តែសាប័នឯករាជ្យមួយដែលបង្កើតឡើងដោយច្បាប់ ឬអនុក្រឹតដែលចេញដោយស្ថាប័ននីតិប្រតិបត្តិ ដើម្បីកំណត់ពីអង្គហេតុ និងបរិបទនៃការរំលោភសិទ្ធិមនុស្ស ឬច្បាប់មនុស្សអន្តរជាតិកាលពីអតីតកាលរបស់ប្រទេសមួយ ។[៣៨] អាណត្តិរបស់ស្ថាប័នរដ្ឋមានលក្ខណៈទូលំទូលាយ ដែលអាចគ្របដណ្តប់លើរាល់បទឧក្រិដ្ឋកម្មសម្ងាប់រង្គាលនាពេលកន្លងមក និងអាចស្តាប់សំឡេងរបស់ជនរងគ្រោះ និងជនដៃដល់ក្នុងចំនួនច្រើនលើសលុបបាន ។ នៅក្នុងករណីខ្លះ គណៈកម្មការការពិតបានបង្កើតសេចក្តីព្រមព្រៀងចងកាតព្វកិច្ចមួយដោយចែងថា រដ្ឋត្រូវតែអនុវត្ត ហើយនៅក្នុងករណីផ្សេងទៀតរដ្ឋាភិបាលមានកាតព្វកិច្ចរាយការណ៍ជាសាធារណៈស្តីពីស្ថានភាពនៃអនុវត្តនេះ ។[៣៩] នៅ

---

[៣៦] សូមមើល De Langis, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលេ ។ ទំព័រ៥៥ដល់៥៦ ។ សូមមើល U.N.Doc.S/RES/១៣២៥ (២០០០);U.N.Doc.S/RES/១៨២០(២០០៨) ។

[៣៧] សូមមើល, បេនី យេ, ដូចកំណត់សម្គាល់ជើងទំព័រទី១៧ ខាងលើ ។

[៣៨] សូមមើល, Eduardo Gonzalez, Drafting a Truth Commission Mandate – A Practical Tool, International Center for Transitional Justice (ខែមិថុនា ឆ្នាំ២០១៣) ទំព័រទី៣ដល់ទី៨ ។ អាចរកមើលបានតាមរយៈគេហទំព័រ http://ictj.org/sites/default/files/ICTJ-Report-DraftingMandate-Truth-Commission-2013_0.pdf.

[៣៩] OHCHR, Rule-of-Law Tools for Post-Conflict States-Commissions (២០០៦), នៅលេខ១៣, អាចមើលបាននៅលើគេហទំព័រ http://ictj.org/sites/default/files/ICTJ-Report-DraftingMandate-Truth-Commission-2013_0.pdf.

ពុំទាន់មានការអនុវត្តមុខងារណាមួយក្នុងចំណោមមុខងារទាំងនោះ ត្រូវបានបំពេញដោយវេទិកាស្តាប់សំឡេងស្ត្រីនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។

បន្ថែមពីលើនេះ វេទិកាស្តាប់សំឡេងស្ត្រីត្រូវបានបង្កើតឡើងដោយឯករាជ្យពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ដោយសារតែ ស្ថាប័នទាំងពីរត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌនៃដំណើរការយុត្តិធម៌អន្តរកាល និងដើម្បីដោះស្រាយចំណុចសំខាន់ទាំងបួនដែលបានរៀបរាប់ពីខាងលើ ដូច្នេះមានការចោទសួរថា ថាតើគេត្រូវជ្រើសរើសយកមួយ ហើយបោះបង់ចោលមួយឬយ៉ាងណា? ចម្លើយគឺច្បាស់ខ្លាំងណាស់ៈ ទេ ។ យន្តការទាំងពីរបំពេញមុខងារផ្សេងគ្នា និងស្ថិតនៅក្រោមការគ្រប់គ្រងផ្សេងគ្នា ដោយពុំមានតួនាទីត្រួតគ្នាឡើយ ។

ការរៀបរាប់របស់បុគ្គលម្នាក់ៗគឺជារឿងសំខាន់ដើម្បីស្វែងរកការពិត ហើយវេទិកាស្តាប់សំឡេងស្ត្រីពុំមែនរៀបចំឡើងដើម្បីរំពុកនូវព្រឹត្តិការណ៍កាលពីអតីតកាលទូទៅដូចជាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានោះទេ ។ ទោះបីជា ទិដ្ឋភាពមួយចំនួននៃយុត្តិធម៌ត្រូវបានផ្តល់ជូនតាមរយៈវេទិកាស្តាប់សំឡេងស្ត្រ ប៉ុន្តែជនល្មើសដែលបានប្រព្រឹត្តបទឧក្រិដ្ឋត្រូវតែទទួលខុសត្រូវចំពោះទោសកំហុសរបស់ខ្លួនដើម្បីឲ្យជនរងគ្រោះអាចទទួលបានយុត្តិធម៌ពេញលេញ និងដើម្បីកុំឲ្យមេដឹកនាំរដ្ឋប្រើប្រាស់អំណាចបំពានលើអ្នកដទៃ ។ ដំណើរការនៃការកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាក៏ចាំបាច់ដើម្បីធានានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ និងបទដ្ឋានច្បាប់អន្តរជាតិដទៃទៀតដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិរបស់ពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយឯករាជ្យ និងមិនលំអៀង ឬការហាមឃាត់ចំពោះការផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយ ។[៤០]

ចំណុចខ្សោយរបស់វេទិកាស្តាប់សំឡេងរបស់ស្ត្រី គឺកង្វះខាតនៃការគាំទ្រពីរដ្ឋ ។ ការផ្តួចផ្តើមឲ្យមានសង្គមស៊ីវិល គឺត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលដើម្បីបំពេញចន្លោះខ្វះខាតដែលអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាពុំបានដោះស្រាយ ហើយលទ្ធផលសម្រេចបាន និងសារសំខាន់នៅក្នុងដំណើរយុត្តិធម៌អន្តរកាលនៅមានកម្រិតនៅឡើយ ។ ទាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ទាំងរាជរដ្ឋាភិបាលពុំបានផ្តល់ការគាំទ្រ និងទទួលស្គាល់វេទិកាស្តាប់សំឡេងស្ត្រីថាជាវិធានការក្រៅប្រព័ន្ធតុលាការផ្លូវការ ដើម្បីដោះស្រាយបញ្ហាកាលពីអតីតកាលនៅឡើយទេ ។ យន្តការនានាត្រូវបានបង្កើតឡើង និងទទួលបានការគាំទ្រពីរដ្ឋ ដូចជា អង្គជំនុំ

---

[៤០] សូមមើល, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ៩៩៩ U.N.T.S ១៧១ និង ១០៥៧ U.N.T.S ៤០៧/[៤០៧] A.T.S. ២៣/៦ L.L.M. ៣៦៨ (១៩៦៧), មាត្រា១៤ ។

ជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីបង្កើតជាទម្រង់ស្នូលនៃដំណើរការយុត្តិធម៌អន្តរកាលដែលទទួលបានជោគជ័យ ដែលបានទាមទារឲ្យមានការដឹកនាំ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅក្នុងប្រទេសក្រោយជម្លោះ ។

ចំណុចសំខាន់ដែលបានរៀបរាប់ខាងលើទាក់ទងនឹងយុត្តិធម៌អន្តរកាល អាចដោះស្រាយតាមរយៈសកម្មភាពរបស់រដ្ឋ ។ មានតែយន្តការដែលគ្រប់គ្រងដោយរដ្ឋទាក់ទងនឹងកម្មវិធីស្វែងរកការពិត ការនិយាយពីការពិត និងសំណង ប៉ុណ្ណោះទើបអាចចូលរួមចំណែកដើម្បីជួយអ្នកដែលរស់រានមានជីវិត និងដើម្បីផ្តល់ឱកាសឲ្យអតីតជនដៃដល់ក្នុងការរៀបរាប់រឿងរ៉ាវកាលពីអតីតកាល ។ មានតែយន្តការដែលគ្រប់គ្រងដោយរដ្ឋប៉ុណ្ណោះ ទើបអាចផ្តល់យុត្តិធម៌បាន ដោយសាររដ្ឋមានឯកសិទ្ធិក្នុងការចោទប្រកាន់ និងផ្តន្ទាទោស រាល់បទឧក្រិដ្ឋដែលកើតឡើងនៅក្នុងរដ្ឋនោះ ហើយមានតែកំណែទម្រង់ដែលធ្វើដោយរដ្ឋប៉ុណ្ណោះ ទើបអាចធានាបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីបំពេញបាននូវការប្តេជ្ញាចិត្តដែលធានាមិនឲ្យកើតមានអំពើបែបនេះកើតឡើងវិញសាជាថ្មីម្តងទៀត ។

## ៥) សេចក្តីសន្និដ្ឋាន

វេទិកាស្តាប់សំឡេងស្ត្រីពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ក្នុងអំឡុងស្ថានភាពជម្លោះ បានរួមចំណែកដល់ដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា ដោយផ្តល់នូវវេទិកាមួយសម្រាប់ជនរងគ្រោះដើម្បីស្វែងរកចំណុចសំខាន់បួនគឺ ការពិត យុត្តិធម៌ សំណង និងការធានាមិនឲ្យកើតមានអំពើបែបនេះសាជាថ្មីម្តងទៀត ។ វេទិកាទាំងនោះ ជាយន្តការក្រៅប្រព័ន្ធតុលាការដែលអនុវត្តអាណត្តិការងារនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលផ្តោតទៅលើបុគ្គលដែលរៀបរាប់ពីដំណើររឿងកាលពីអតីតកាល និងជនរងគ្រោះ ។ សម្រាប់អ្នកដែលរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ មិនត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការរបស់តុលាការនោះទេ ប៉ុន្តែអ្នកទាំងនោះត្រូវការគាំទ្រ និង ផ្តល់តម្លៃជាពិសេស ។ ប្រសិនបើសំណុំរឿង០០៤ បានដំណើរការទៅមុខជាមួយការចោទប្រកាន់ពីការរំលោភសេពសន្ថវៈ ដែលនៅក្រៅបរិបទនៃការបង្ខំឲ្យមានការរៀបការនោះ វេទិកាស្តាប់សំឡេងស្ត្រីគួរតែត្រូវបានផ្តល់តម្លៃជាមួយនឹងការជំរុញអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ឲ្យបាត់វិធានដោះស្រាយលើបញ្ហានេះ ។[៤១]

[៤១] នៅក្នុងករណីដែលសំណុំរឿង០០៤មិនត្រូវបាននាំយកមកជំនុំជម្រះ ចាំបាច់ត្រូវមានការពិនិត្យលើលទ្ធភាពក្នុងការបោះពុម្ពផ្សាយភស្តុតាងដែលប្រមូលបានទាក់ទងនឹងបញ្ហាអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដែលប្រឆាំងនឹងស្ត្រីក្នុងគោលបំណងអប់រំ និងចងក្រងឯកសារនានា ។

ទម្រង់នៃវេទិកាស្តាប់សំឡេងស្ត្រីអាចយកទៅអនុវត្តជាមួយនឹងជនដែលរងគ្រោះផ្សេងទៀត ដូចជា ក្រុមជនជាតិភាគតិចដែលទទួលរងនូវការរើសអើងនាពេលបច្ចុប្បន្ន ។ ដូចគ្នាទៅនឹងស្ថានភាពរបស់អ្នកដែលរស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទ និងបញ្ហាយេនឌ័រ ដែរ ក្រុមមនុស្សរងគ្រោះផ្សេងទៀតដែលមានបទពិសោធន៍ក្នុងអំពើហិង្សា ហើយមិនត្រូវបានដាក់បញ្ចូលសំណុំរឿងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា គឺចាំបាច់ត្រូវមានវេទិកាមួយដើម្បីបង្ហាញពីបទពិសោធន៍របស់អ្នកទាំងនោះ ដែលធានាឲ្យមានបរិស្ថានសុវត្ថិភាព និងទទួលបានការគាំទ្រយ៉ាងកក់ក្តៅសម្រាប់ការចូលរួមរបស់គាត់ ។ ឧទាហរណ៍ៈ ខ្មែរកម្ពុជាក្រោមធ្លាប់បានទទួលរងគ្រោះអំពើហិង្សាដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម មិនត្រូវបានដាក់បញ្ចូលទៅក្នុងដីកាដំណោះស្រាយអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា42នោះទេ ។ នៅកង់ទស្សនៈនៃការរើសអើងប្រឆាំងនឹងក្រុមជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជា[៤៣] នាពេលបច្ចុប្បន្ននេះ វេទិកាមួយចំនួនដែលមានទម្រង់ជាវេទិកាស្តាប់សំឡេងស្ត្រីអាចធានាបាននូវកម្រិតនៃការការពារ ប៉ុន្តែស្របពេលជាមួយគ្នានេះ ការឈឺចាប់ និងបទឧក្រិដ្ឋដែលប្រឆាំងនឹងគាត់ក៏ត្រូវបានទទួលស្គាល់ដែរ ។

ទោះបីជាវេទិកាស្តាប់សំឡេងស្ត្រីពុំមែនផ្តួចផ្តើមគំនិតដោយរាជរដ្ឋាភិបាលក៏ដោយ ក៏វេទិកានេះនៅមានកម្រិតនៅក្នុងសកម្មភាពការងារ វិសាលភាព និងផលប៉ះពាល់ ។ នៅក្នុងទស្សនៈទាក់ទងនឹងសក្តានុពលនៃវេទិកាស្តាប់សំឡេងស្ត្រីក្នុងការដោះស្រាយការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាអំពីការប្រើប្រាស់ទម្រង់នៃវេទិកាក្រៅប្រព័ន្ធតុលាការសម្រាប់ជនរងគ្រោះ ដើម្បីធ្វើជាមធ្យោបាយបំពេញកាតពកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិក្នុងការផ្តល់សំណងដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ដូចដែលបានអំពាវនាវដោយគណៈកម្មាការត្រួតពិនិត្យការអនុវត្តនអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ។ នៅក្នុងកំណត់សម្គាល់មួយរបស់គណៈកម្មាធិការនេះ បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវបានស្នើឲ្យអភិវឌ្ឍកម្មវិធីយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការដែលមានប្រសិទ្ធភាព ក្នុងនោះរួមមាន ការផ្តល់សំណងគ្រប់គ្រាន់, ការព្យាបាល

[៤២] ដោយសារតែមានសំណើសុំឲ្យមានការស៊ើបអង្កេតរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឲ្យមានការស៊ើបអង្កេតពីបទឧក្រិដ្ឋប្រឆាំងនឹងជនជាតិភាគតិចកម្ពុជាក្រោមនៅក្នុងសំណុំរឿង០០៤ ។ សេចក្តីប្រកាសព័ត៌មាន, សេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងទៅនឹងសំណុំរឿង០០៤ (ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១) ។

[៤៣] សូមមើល, Kevin Ponniah & Seangly, *ខ្មែរជនជាតិភាគតិចមិនមានសិទ្ធិស្មើគ្នា ភ្នំពេញប៉ុស្តិ៍*, ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៤, អាចរកមើលបានលើគេហទំព័រ www.phnompenhpost.com/national/khmer-minority-lack-equal-rights-report.

របួសផ្លូវចិត្ត និងការគាំទ្រផ្នែកផ្សេងៗទៀតសម្រាប់ជនរងគ្រោះដោយសារ អំពើហិង្សាយេនឌ័រដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។[៤៤]

[៤៤] ការកត់សម្គាល់លើរបាយការណ៍ពិនិត្យមើលការអនុវត្តអនុសញ្ញាស្ដីពីការលុបបំបាត់ការរើសអើងដែលប្រឆាំងនឹងស្ត្រីនៅកម្ពុជា ដែលផ្ញើរួមគ្នាលើទីបួន និងទីប្រាំ, សម័យប្រជុំលើកទី៥៦, U.N. Doc. CEDAW/C/KHM/CO/៤-៥ (២០១៣) ។